ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០១........សហវ.ភ.ក.ភ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ
## នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣២៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មធិការកែទម្រង់រដ្ឋបាលសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ “**ក.រ.ស.កសហវ.**” និងមានសមាសភាពដូចខាងក្រោម÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

| | | |
|---|---|---|
| ១- ឯកឧត្តម **មាស សុខសេនសាន** | រដ្ឋលេខាធិការ កសហវ. | ប្រធាន |
| ២- ឯកឧត្តម **ឯក ចន្ថា** | អគ្គលេខាធិការ កសហវ. | អនុប្រធាន |
| ៣- លោក **ពៅ រិទ្ធជ័យសិទ្ធ** | អគ្គលេខាធិការរង កសហវ. | សមាជិក |
| ៤- លោក **ប៊ិន ភក្កដា** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិកអចិន្ត្រៃយ៍ |
| ៥- លោក **ទុំ ម៉ុងហេង** | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៦- លោក **ខៀម ប្រសើរ** | ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន | សមាជិក។ |

**ប្រការ២._**

"**ក.រ.ស.កសហវ.**" មានភារកិច្ចដូចខាងក្រោម÷

- ដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្នុងនោះផ្ដោតទៅលើ÷ (១) ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី (២) ការលើកកម្ពស់ប្រសិទ្ធភាពការងារ និង (៣) ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម
- អនុវត្តការត្រួតពិនិត្យឡើងវិញ និងវិភាគមុខងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ និងអភិវឌ្ឍកម្មវិធីពង្រាយមន្ត្រីរាជការ និងស្ថាប័ន
- រៀបចំ និងអភិវឌ្ឍកម្មវិធីដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី និងស្ថាប័ន
- រៀបចំផែនការសកម្មភាពការងារកែទម្រង់ក្នុងដែនសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយបន្សុីទៅនឹងវិធានការគន្លឹះទាំងបីរបស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ចូលរួមកិច្ចប្រជុំទៀងទាត់ប្រចាំត្រីមាសនិងផ្អែកតាមការចាំបាច់ តាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពិនិត្យវឌ្ឍនភាពការងារ បញ្ហាប្រឈម ដំណោះស្រាយ និងវិធានការនានា
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីវឌ្ឍនភាពការងារជា ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំរបាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្តតួនាទីនិងភារកិច្ចរបស់**ក.រ.ស.កសហវ.** ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ (នៅសប្ដាហ៍ទី៣នៃខែចុងក្រោយ) ជូននាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃនៃអគ្គលេខាធិការ-ដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធ្វើការបូកសរុបរាយការណ៍ជូនគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មុនពេលដាក់ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៣._**

នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបំពេញមុខងារជាលេខាធិការដ្ឋាន នៃ "**ក.រ.ស.កសហវ.**" ជាសេនាធិការ សម្របសម្រួលរួមលើការអនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមការងារ ដែលមានសមាស-ភាពដូចខាងក្រោម÷



H-

| | | |
|---|---|---|
| ១- លោក **ឌិន ភក្តដា** | ប្រធាននាយកដ្ឋានបុគ្គលិក | ប្រធាន |
| ២- លោកស្រី **ថោង វណ្ណសុជីវី** | អនុប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| ៣- លោក **ប៊ួយ វណ្ណាហឿន** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤- លោក **ស៊ុំ ស៊ីផាណ្ណា** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៥- លោក **លី នាងខត្តិយា** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦- លោកស្រី **ឥន ដារ៉ា** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧- លោកស្រី **ឃួន បូរ៉ាត្ន** | ប្រធានការិយាល័យបុគ្គលិក | សមាជិក |
| ៨- លោកស្រី **តាំង សៅរ៍កម្ពុយ** | ប្រធានការិយាល័យបៀវត្ស | សមាជិក |
| ៩- លោក **ថន ចាន់ដារ៉ា** | ប្រធានការិយាល័យត្រួតពិនិត្យបុគ្គលិក | សមាជិក |
| ១០- លោក **ឆុយ សុខហេង** | ប្រធានការិយាល័យគ្រប់គ្រងការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១១- លោក **ម៉ា បូរិទ្ធ** | ប្រធានការិយាល័យគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ | សមាជិក |
| ១២- លោក **អៀង គីមលីន** | អនុប្រធានការិយាល័យត្រួតពិនិត្យបុគ្គលិក | លេខាធិការ។ |

**ប្រការ៤.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.**_

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ គ្រប់ប្រធានអង្គភាព នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួន ដូចមានរាយនាមក្នុងប្រការ ១ និងប្រការ ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ៧រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

  **“ដើម្បីជូនជ្រាប”**
- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ